00942621

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01 / 08 / 2013
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/193

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២០ ខែ ឧសភា ឆ្នាំ ២០១៣

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ១៨០

រៀបចំដោយ៖ **ដាវ អានសាន** និង **Matteo CRIPPA**

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក ឌុច ផារី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន, លោក Keith RAYNOR |
| ជនជាប់ចោទ៖ ខៀវ សំផន និង នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, |

| |
|---|
| លោកស្រី ដេត វ៉ាន់លី, លោកស្រី Christine MARTINEAU, លោក សំ សុគង់, លោក ឡៅ ជុនធី, លោក ហុង គឹមសួន, លោក Pascal AUBOIN |
| សាក្សី៖ TCW-253 (លោក អៀង ផាន) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី ស្វ សុទ្ធាវី, លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Grant RAGLAND |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការតាំងសំណួរចំពោះសាក្សី អៀង ផាន (TCW-253) | អង្គជំនុំជម្រះសាលាដំបូង | ០៩.០៩ | ០៩.១៧ |
| | តំណាងសហព្រះរាជអាជ្ញា | ០៩.១៧ | ១១.១៩ |
| | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១១.១៩ | ១២.០៤ |
| | មេធាវីការពារក្តី នួន ជា | ១៣.៣៣ | ១៥.០៨ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៥.០៨ | ១៥.៣៩ |
| កាលបរិច្ឆេទសវនាការស្តាប់ការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះសាលាដំបូង | ១៥.៤១ | ១៥.៥៤ |
| ការពិភាក្សាលើសំណើសុំផ្ទាល់មាត់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៥.៥៤ | ១៦.០៥ |
| | តំណាងសហព្រះរាជអាជ្ញា | ១៦.០៥ | ១៦.១០ |
| | មេធាវីការពារក្តី នួន ជា | ១៦.១០ | ១៦.១១ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៦.១១ | ១៦.១៤ |

| | | | |
|---|---|---|---|
| | សហមេធាវីនាំមុខតំណាង ដើមបណ្ដឹងរដ្ឋប្បវេណី | ១៦.១៤ | ១៦.១៦ |
| | អជសង | ១៦.១៩ | ១៦.២០ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការតាំងសំណួរចំពោះសាក្សី អៀង ផាន (TCW-253)**

អង្គជំនុំជម្រះចាប់ផ្ដើមដោយប្រាប់ពីសិទ្ធិនិងកាតព្វកិច្ចដល់សាក្សី។ តំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានវេលាកន្លះថ្ងៃសវនាការ ដើម្បីតាំងសំណួរដល់សាក្សី។ ជាបន្តបន្ទាប់ មេធាវីការពារក្ដី នួន ជា និងមេធាវី ខៀវ សំផន មានវេលាកន្លះថ្ងៃ ដើម្បីតាំងសំណួររហូតដល់បញ្ចប់សក្ខីកម្មរបស់សាក្សីរូបនេះ។

**កាលបរិច្ឆេទសវនាការស្ដាប់ការថ្លែងទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

អង្គជំនុំជម្រះសាលាដំបូងជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ចំនួន ៤ ថ្ងៃ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីមានឱកាសថ្លែងទុក្ខសោករបស់ខ្លួន ពោលគឺថ្ងៃទី ២៧, ២៩, ៣០ ខែ ឧសភា ឆ្នាំ ២០១៣ និងថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣។ អជសង ក៏នឹងស្ដាប់សក្ខីកម្មអ្នកជំនាញ TCE-12 រយៈពេលកន្លះថ្ងៃ នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣។

**ការពិភាក្សាលើសំណើផ្ទាល់មាត់របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីការថ្លែងទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើដល់ អជសង ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងមកថ្លែងសារទុក្ខរបស់ខ្លួន បានចាកចេញពីសវនាការ មុនពេលដែលភាគីទាំងអស់ពិភាក្សាដេញដោលលើសេចក្ដីថ្លែងទាំងនោះ និងអត្ថន័យជាសារវ័ន្តរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងទុក្ខសោករបស់ខ្លួន។ ជាបន្តបន្ទាប់ មេធាវី នួន ជា និងខៀវ សំផន មានពេលវេលាម្នាក់ ៥នាទី ដើម្បីធ្វើសារណាតបដោយផ្ទាល់មាត់។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសារណាផ្ទាល់មាត់តប។ អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្ដីណែនាំក្នុងពេលឆាប់ៗ។

## កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង

| លេខ E3 | លេខ កសចស | ERN | ចំណងជើង | ចំណាត់ថ្នាក់ | សម្គាល់ជាភាសាខ្មែរ | សម្គាល់ជាភាសាអង់គ្លេស | សម្គាល់ជាភាសាបារាំង |
|---|---|---|---|---|---|---|---|
| E3/419 | D234/19 | 00407745-00407752 00411002-00411009 00434784-00434790 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន IENG Phan<br>Written Record of Interview of IENG Phan អៀង ផាន<br>Procès verbal d'audition de témoin IENG Phan អៀង ផាន | P | 00407750, 00407749 | 00411007 | 00434788, 00434787 |
| E3/361 | D123/2 | 00194462-00194473 00766447-00766459 00268878-00268892 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន<br>[Corrected 1] Written Record of Interview of CHHOUK Rin<br>[Corrigé 1] Procès verbal d'audition de CHHOUK Rin | P | 00194462 | | |
| E3/5 | D243/2.1.1 | 00063311-00063353 00401476-00401511 00538951-00538985 | ទង់បដិវត្ត លេខ ៨ សីហា ១៩៧៥<br>CPK Magazine entitled: " The Revolutionary Flag", Issue 8, August 1975 (FULL)<br>CPK Magazine entitled: " The Revolutionary Flag", Issue 8, August 1975 (FULL) | P | | | |
| E3/798 | 13.28 | 00052380-00052383 00183966-00183969 00386196-00386200 | កំណត់ហេតុនៃការប្រជុំលេខា, អនុលេខាកងពល និង វរៈសេនាធំឯករាជ អំពីពិនិត្យសភាពការណ៍ខ្មាំង និងចាត់វិធានការ<br>Note of Secretary, Under-secretary Division and Independence Regiment Meeting. About Controlling enemy situation and take measures.<br>Note of Secretary, Under-secretary Division and Independence Regiment Meeting. About Controlling enemy situation and take measures. | P | 00052382 | 00183968 | 00386199 |

## ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖

- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី TCW-253 និងសាក្សីបម្រុង TCW-548 ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់វិញ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ

00942625



អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការវិញ និងជនជាប់ចោទ នួន ជា មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ ឲ្យបានមុន ម៉ោង ០៩.០០ នាទី ព្រឹក ។

<u>**កាលបរិច្ឆេទបន្តសវនាការ៖**</u>

សវនាការនឹងបន្តនៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ០៩ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ដាវ អានសុខ Matteo CRIPPA**